ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ១២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាពការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែធ្នូ ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការដាក់ឲ្យអនុវត្តនូវវិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៦ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែតុលា ឆ្នាំ២០១៤ | ៨ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៦ |

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការដាក់ឲ្យអនុវត្តនូវវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និងឯកឧត្តម **អ៊ុំ ប៊ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការដាក់ឲ្យអនុវត្តនូវវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក មន្ត្រី និងតំណាង នៃECOSOCC សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយក រដ្ឋមន្ត្រី **សុខ អាន** និងមន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី។



វិធីសាស្ត្រនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត Regulatory Impact Assessment (ហៅថា "វិធីសាស្ត្រRIA") ត្រូវបាននឹងកំពុងអនុវត្តជាផ្លូវការនៅក្នុងប្រទេស ចំនួនជាង ៦០(1) លើពិភពលោក ហើយប្រទេសទាំងនេះបានទទួលស្គាល់គុណតម្លៃនៃវិធីសាស្ត្រនេះ ដែលជាឧបករណ៍មួយសម្រាប់វិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តទាំងនោះឲ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ ដែលជាកត្តាមួយជួយលើកកម្ពស់ផលិតភាព និងការប្រកួតប្រជែង(2)។

ប្រទេសកម្ពុជាមិនទាន់មានបទប្បញ្ញត្តិណាតម្រូវឲ្យមានការអនុវត្តវិធីសាស្ត្រ RIA ជាផ្លូវការនៅឡើយទេ តែបានអនុវត្តសាកល្បងនូវវិធីសាស្ត្រRIAជាង ៣ឆ្នាំមកហើយ គឺតាំងពីខែតុលា ឆ្នាំ២០១១ ក្រោមគម្រោង

(1) សមាជិក OECD (EU, UK, USA etc.), នៅអាស៊ាន វៀតណាមជាប្រទេសទី១ ដែលបានកំណត់ក្នុងច្បាប់ឲ្យអនុវត្តវិធីសាស្ត្រ RIA ចាប់តាំងពីឆ្នាំ២០០៩

(2) Best-Practice Regulation Handbook, Australian Government, Jun 2010

វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ហៅកាត់ថាគម្រោងRIA ក្រោមហិរញ្ញប្បទានឥតសំណង ពីធនាគារអភិវឌ្ឍន៍អាស៊ី(ADB) លេខ 0224-CAM (SF) ដែលជាអនុគម្រោង ក្រោមកម្មវិធីជំរុញពិពិធកម្មសេដ្ឋកិច្ច (Prooting Ecomomic Diversification-Subprogam 2 (PED-SP2)) បន្ទាប់ពីកម្មវិធីកំណែទម្រង់ដែលបានអនុវត្តក្នុងPED-SP1។ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី បាននឹងកំពុងប្រតិបត្តិគម្រោងនេះដែលមានក្រសួងចំនួន៧ចូលរួមអនុវត្តគម្រោង គឺមានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។ គម្រោងRIAនេះនឹងត្រូវបញ្ចប់នៅខែមីនា ឆ្នាំ២០១៥ ក្រោយពីADB បានពន្យារនិងបន្ថែមថវិកាសម្រាប់ប្រតិបត្តិការគម្រោងពីរដងមក គឺលើកទី១នៅខែមករាឆ្នាំ២០១៤ និងលើកទី២នៅ ខែកញ្ញាឆ្នាំ២០១៤ នៅពេលដែលADBគ្រោងដំណើរការគម្រោងបច្ចេកទេស(TA)ថ្មីនៅចុងត្រីមាសទី១ ឆ្នាំ២០១៥ សម្រាប់គាំទ្រកម្មវិធីRIAថ្នាក់ជាតិពី២០១៥ ដល់២០១៧។ ក្រសួងចូលរួមអនុវត្តគម្រោងទាំង៧បានសម្រេចរបាយការណ៍វាយតម្លៃបឋម ចំនួន ២២ ភាគច្រើនធ្វើលើប្រកាស និងកំពុងរៀបចំរបាយការណ៍វាយតម្លៃបឋមនិងរបាយការណ៍វាយតម្លៃពេញលេញចំនួន៩ បន្តទៀត។ ចំពោះគោលការណ៍ណែនាំស្ដីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតដ្ឋានគតិយុត្តផ្សេងទៀត ដែលបានចេញនៅឆ្នាំ២០១៣ មានចែងតែពីទម្រង់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តតែប៉ុណ្ណោះ។

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានឯកភាពជាគោលការណ៍ឲ្យ ECOSOCC រៀបចំសេចក្ដីព្រាងបទប្បញ្ញត្តិស្ដីពីការដាក់ឲ្យអនុវត្តនូវវិធីសាស្ត្រនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត សម្រាប់វាយតម្លៃលើផលប៉ះពាល់នៃសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តដែលមានផលប៉ះពាល់ដល់ធុរកិច្ច និងវិនិយោគ តាមការស្នើសុំពីទីស្ដីការគណៈរដ្ឋមន្ត្រី។ ឯកឧត្ដមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បានណែនាំឲ្យ ECO-SOCC រៀបចំសេចក្ដីព្រាងបទប្បញ្ញត្តិនេះជាព្រះរាជក្រឹត្យ ដូចបានដាក់ជូនពិនិត្យនាពេលនេះ។

បច្ចុប្បន្នក្រសួង ស្ថាប័ន ដែលជាអ្នកមានភារកិច្ចរៀបចំតាក់តែងសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត (មាន ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសជាដើម) ដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន ហើយបន្ទាប់មកផ្ញើមកទីស្ដីការគណៈរដ្ឋមន្ត្រីនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួន (ចាប់ពីអនុក្រឹត្យឡើងទៅ) ដែលសុំឆ្លងអង្គប្រជុំតាមនីតិវិធី ដោយភ្ជាប់មកជាមួយសេចក្ដីព្រាងនោះ នូវសេចក្ដីថ្លែងហេតុ និងឯកសារយោង ក៏ប៉ុន្តែមិនធ្លាប់មានរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តនោះទេ ដោយសារមិនទាន់មានបទប្បញ្ញត្តិដែលតម្រូវឲ្យអនុវត្ត។ ចំណែកឯសេចក្ដីថ្លែងហេតុ មានលើកឡើងពីហេតុផល និងការវាយតម្លៃលើផលវិបាករបស់សេចក្ដីព្រាងដែរ ក៏ប៉ុន្តែមិនបានសិក្សាវាយតម្លៃឲ្យបានស៊ីជម្រៅ ដូចរបាយការណ៍វាយតម្លៃលើផលប៉ះពាល់ទៅតាមវិធីសាស្ត្រRIAនោះទេ។



ECOSOCC ពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តណាដែលដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី ដោយធ្វើការវិភាគលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច ក៏ប៉ុន្តែការវិភាគនេះនៅមានកម្រិតនៅឡើយ ដោយសារកង្វះព័ត៌មានពីក្រសួង ស្ថាប័ន និងកង្វះវិធីសាស្ត្រRIAដែលជាវិធីសាស្ត្រមានការវិភាគលើបន្ទុកចំណាយ និងផលចំណេញ ដែលត្រូវធ្វើឡើងដោយក្រសួង ស្ថាប័នសាមីដែលជាអ្នកលើកសំណើ។ ECOSOCC បានកែលម្អនិងកាត់បន្ថយចំណុចអវិជ្ជមានបានមួយកម្រិតនៃសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តទាំងនោះ។ តែបញ្ញត្តិកម្មឯទៀតដែលគ្មានយន្តការត្រួតពិនិត្យ ដូចប្រកាសនិងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត អាចនឹងដាក់បន្ទុកចំណាយកាតព្វកិច្ចមិនចាំចាច់ជាច្រើនដល់អ្នកអនុវត្ត(3) បើគ្មានការប្រុងប្រយ័ត្ន។

ជាងនេះទៀត អាស៊ានមានគោលការណ៍ណែនាំស្តីពីទម្លាប់អនុវត្តល្អក្នុងការតាក់តែងលិខិតបទដ្ឋានបច្ចេកទេស ដែលបានណែនាំឲ្យបណ្តារដ្ឋជាសមាជិកឲ្យអនុវត្តRIAក្នុងដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្ត(4)។ ម្យ៉ាងទៀតតាមរបាយការណ៍ស្តីពីភាពងាយស្រួលក្នុងដំណើរការធុរកិច្ចចេញនៅឆ្នាំ២០១៤ ដោយធនាគារពិភពលោក បានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានូវលេខរៀងទី ១៣៧ ក្នុងចំណោមប្រទេស ១៨៩(5)។ ចំណាត់ថ្នាក់របស់កម្ពុជានេះស្ថិតនៅក្រោមចំណាត់ថ្នាក់ប្រទេសអាស៊ានភាគច្រើន តែស្ថិតនៅលើចំណាត់ថ្នាក់ប្រទេសឡាវ និងមីយ៉ាម៉ា។ ក្នុងន័យនេះ កម្ពុជាគួរពិនិត្យប្រសិទ្ធភាពនៃការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានផលប៉ះពាល់ដល់ធុរកិច្ច និងវិនិយោគ។ ដូច្នេះវិធីសាស្ត្រRIA ជាឧបករណ៍ជួយលើកកម្ពស់គុណភាពនៃការរៀបចំសំណើលិខិតបទដ្ឋានគតិយុត្តទាំងនោះ។

(3) Cambodia Regulatory Impact Assessment Strategic Plan, August 2010

(4) ASEAN Good Regulatory Practice Guide (Endorsed by the 2/40 SEOM Meeting, 2-4 February 2009, Bangkok, Thailand)

(5) Doing Business 2014 (Understanding Regulations for Small and Medium Size Enterprises), by IFC/WB

សង្គមសេដ្ឋកិច្ចជឿនលឿនទាមទារឲ្យមានលិខិតបទដ្ឋានគតិយុត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ដើម្បីគ្រប់គ្រងសេដ្ឋកិច្ចសង្គម ឲ្យបានរលូននិងចម្រុងចម្រើនតាមទាន់ដំណើរការវិវត្តរបស់ពិភពលោកបច្ចុប្បន្ន។

ការដាក់បញ្ញត្តិឲ្យអនុវត្តវិធីសាស្ត្រRIAក្នុងដំណើររៀបចំសេចក្តីព្រាងព្រាងលិខិតបទដ្ឋានគតិយុត្តមានគោលបំណងលើកកម្ពស់គុណភាពនៃលិខិតបទដ្ឋានគតិយុត្ត កាត់បន្ថយហានិភ័យ ការិយាធិបតេយ្យ និងបន្ទុកចំណាយកាតព្វកិច្ចដែលមិនចាំបាច់ ដើម្បីជំរុញការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្ម និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងរួមចំណែកលើកកម្ពស់ផលិតភាពនិងសមធម៌សង្គម។

គម្រោងRIAនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២ ក្រោមអធិបតីឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានថ្នាក់ដឹកនាំ និងមន្ត្រីជំនាញមួយចំនួនមកពី២៧ក្រសួងនិងស្ថាប័ន និស្សិតមួយចំនួនមកពី៦ឧត្តមសិក្សា និងតំណាងដៃគូអភិវឌ្ឍន៍ចំនួន៧បានមកចូលរួម។ បន្ទាប់មក ក្រុមការងារគម្រោងRIA នៃECOSOCC បានសហការជាមួយADB រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ពិគ្រោះយោបល់អំពីគម្រោងនិងវិធីសាស្ត្រRIA ចំនួន ៣២ដង ជាមួយវិស័យ ឯកជន សង្គមស៊ីវិល ថ្នាក់កំរិតឧត្តមសិក្សាចំនួន៧ ក្រសួងនិងស្ថាប័នរដ្ឋចំនួន៣៧ រួមទាំងអគ្គលេខាធិការដ្ឋានរដ្ឋសភានិងព្រឹទ្ធសភា និងទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានចំនួនសិក្ខាកាមចូលរួមសរុបប្រមាណ ៤៨០០នាក់។ សិក្ខាកាមទាំងអស់ មានចំណាប់អារម្មណ៍ល្អពីវិធីសាស្ត្រRIA និងមានសំណូមពរឲ្យអនុវត្តវិធីសាស្ត្រRIAនេះនៅប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនិងប្រសិទ្ធផលនៃសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត។ សិក្ខាកាមមកពីក្រសួងនិងស្ថាប័នខ្លះ ថែមទាំងមានសំណូមពរចង់ចូលរួមក្នុងកម្មវិធីសាកល្បងនេះផង។

ការអនុវត្តវិធីសាស្ត្រRIAក្នុងដំណើរការព្រាងលិខិតបទដ្ឋានគតិយុត្ត នឹងបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

-ជួយអ្នកសម្រេចចិត្តក្នុងការកំណត់យកជម្រើសល្អជាងគេ ដោយមានមូលដ្ឋានព័ត៌មានគ្រប់គ្រាន់ដើម្បីកាត់បន្ថយនូវហានិភ័យ ការិយាធិបតេយ្យនិងបន្ទុកចំណាយកាតព្វកិច្ចដែលមិនចាំបាច់ សម្រាប់គុណប្រយោជន៍សេដ្ឋកិច្ចជាតិនិងគុណប្រយោជន៍គោលនយោបាយ សាធារណៈ

-បង្កើតដំណើរការដើម្បីត្រួតពិនិត្យ និងទប់ស្កាត់សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តណាដែលមានគុណភាពទាប មុននឹងដាក់ជូនអ្នកធ្វើសេចក្តីសម្រេច

-ធានាគុណភាពនិងសង្គតិភាពនៃលិខិតបទដ្ឋានគតិយុត្ត និងជៀសវាងបញ្ហាជាន់សមត្ថកិច្ចគ្នា

-ពង្រឹងអភិបាលកិច្ចល្អ និងជំរុញតម្លាភាព

-ធ្វើឲ្យសាធារណៈជនមានសេចក្តីទុកចិត្តលើប្រព័ន្ធលិខិតបទដ្ឋានគតិយុត្ត (legal system) និងការគោរពច្បាប់ក៏កាន់តែប្រសើរឡើង

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃពុធ ទី២៤ ខែធ្នូ ឆ្នាំ២០១៤ នៅវេលាម៉ោង១៧:00 នាទីល្ងាច នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងសមាជិក (ECOSOCC) ក្រុមប្រឹក្សាអ្នកច្បាប់ ឯកឧត្តម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក្រសួងសាមី និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

អង្គប្រជុំបានពិភាក្សាលើសេចក្តីព្រាងច្បាប់នេះយ៉ាងល្អិតល្អន់ពិសេសក្នុងមាត្រា២៥ ស្តីពីសិទ្ធិកំណែនដើម្បីប្រតិបត្តិការសង្គ្រោះបន្ទាន់និងឲ្យស្រប មាត្រា៤៤ និង មាត្រា៦០ នៃច្បាប់រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។ អង្គប្រជុំបានសម្រេចកែពាក្យពេចន៍ និងខ្លឹមសារដូចខាងក្រោម៖

មាត្រា៦ កថាខណ្ឌទី២ បន្ទាត់ទី១ លុបឃ្លា "**ត្រូវបានតែងតាំង**" បន្ទាប់ពីពាក្យ "**នាយករដ្ឋមន្ត្រី**"។

មាត្រា៧ កថាខណ្ឌទី២ បន្ទាត់ទី៣ បន្ថែមពាក្យ "**អាវុធហត្ថ**" បន្ទាប់ពីពាក្យ "**នគរបាលជាតិ**"។

មាត្រា១០ បន្ទាត់ទី៣ កែសម្រួលឃ្លា "**កសាងបញ្ញត្តិ**" ទៅជា "**កសាងលិខិតបទដ្ឋានគតិយុត្ត**" ពីមុខពាក្យ "**និងវិធានការពង្រឹង....**"។





មាត្រា១៥ បន្ថែមពាក្យ "**និង**" បន្ទាប់ពីពាក្យ "**ទប់ស្កាត់**"។

មាត្រា២០ កថាខណ្ឌទី២ បន្ទាត់ទី១ កែសម្រួលឃ្លា "**តួអង្គពាក់ព័ន្ធ**" ទៅជា "**ភាគីពាក់ព័ន្ធ**" នៅចន្លោះពាក្យ "**គ្រប់**" និងពាក្យ "**ពិភាក្សា**"។

មាត្រា២៥ នៅដើមកថាខណ្ឌ លុបឃ្លា "**នៅគ្រាមានគ្រោះអាសន្ន**" ជំនួសដោយ "**ក្រោយពីមានការប្រកាសដាក់ប្រទេស ឬតំបន់ស្ថិតនៅក្រោមស្ថានភាពគ្រោះមហន្តរាយ ដូចមានចែងក្នុងមាត្រា២១ នៃច្បាប់នេះ**"។

បន្ថែមឃ្លា "**ដោយមានការឯកភាពពីរាជរដ្ឋាភិបាល**" បន្ទាប់ពីពាក្យ "**ទទួលខុសត្រូវ**"។

បន្ថែមកថាខណ្ឌទី២ "**នីតិវិធីនៃការធ្វើកំណែន និងសំណងត្រូវកំណត់ដោយអនុក្រឹត្យ**"។

មាត្រា២៧ កថាខណ្ឌទី២ បន្ទាត់ទី៣ កែសម្រួលឃ្លា "**តួអង្គពាក់ព័ន្ធ**" ទៅជា "**ភាគីពាក់ព័ន្ធ**" បន្ទាប់ពីពាក្យ "**ជំនាញ**" ។

មាត្រា៣៣ ប្តូរចំណងជើងពី "**ការគោរពច្បាប់និងបទប្បញ្ញត្តិជាតិ**" ទៅជា "**ការគោរពច្បាប់ និងបទដ្ឋានគតិយុត្តជាតិ**"។

មាត្រា៤៥ កថាខណ្ឌទី១ កែសម្រួលឃ្លា "**ត្រូវបន្តលិខិតបទដ្ឋាននានាដែលមានស្រាប់រហូតដល់មានលិខិតបទដ្ឋានថ្មីមកជំនួស។**" ទៅជា "**លិខិតបទដ្ឋានគតិយុត្តនានាដែលកំពុងអនុវត្តត្រូវបន្តមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។**"។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះ នៅម៉ោង ១៨:១៥នាទី។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៤*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា**ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤ ដឹកនាំដោយ ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែវិច្ឆិកាឆ្នាំ២០១៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ ០,៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ : | +៦,៦% | ផ្លែឈើ: | +៩,៥% |
| ភោជនីយដ្ឋាន: | +៥,៦% | សាច់ជ្រូក: | +៨,៨% |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់: | +៥,៤% | សាច់គោ: | +៥,៦% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមានជាតិស្រវឹង | +៣,៨% | សាច់មាន់ស្រស់: | +៣,៦% |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១២–២០១៤

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ[P] | ប្រចាំឆ្នាំ[P] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,០% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,០% |
| | មុន | ០,២% | ០ | ០,៥% | ០,៥% | ០,៣% | ០,៥% | ០,៤% | ០,៣% | ០,២% | -០,៤% | -០,៨% | ០,៧% | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | មុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |
| ២០១២ | ដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | មុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០% | ១,១% | ០,២% | -០,២% | -០,២% | ០% | |

**P**: តួលេខខែធ្នូ និងប្រចាំឆ្នាំ២០១៤ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដេកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | វិច្ឆិកា២០១៤ | តុលា២០១៤ | វិច្ឆិកា២០១៣ | *ប្រភេទ* | វិច្ឆិកា២០១៤ | តុលា២០១៤ | វិច្ឆិកា២០១៣ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៦៣៛/១$ | ៤០៧៦៛/១$ | ៣៩៩៥៛/១$ | **បាត/ដុល្លារ** | ៣២,៧៨បាត/១$ | ៣២,៥៣បាត/១$ | ៣២,១១បាត/១$ |
| **៛/បាត** | ១២៤៛/១បាត | ១២៥៛/១បាត | ១២៤៛/១បាត | **ដុង/ដុល្លារ** | ២១៣៩០ដុង/១$ | ២១២២០ដុង/១$ | ២១០៩០ដុង/១$ |
| **៛/ដុង** | ០,១៩០៛/១ដុង | ០,១៩២៛/១ដុង | ០,១៨៩៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ៖** អនុវត្តបាន៧២៥,៦ពាន់លានរៀល(មធ្យមប្រចាំខែ៩៨% នៃផែនការ)ក្នុងនោះចំណូលចរន្តចំនួន ៧១៩,៤ពាន់លានរៀល(មធ្យមប្រចាំខែ ១០២% នៃផែនការ)និងចំណូលមូលធនមានចំនួន ៦,២ពាន់លានរៀល។

➢បើធៀបនឹងខែមុនចំណូលថវិកាជាតិថយចុះ ១១,៨% ប៉ុន្តែកើនឡើង ១៨,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៦១៩,៨ពាន់លានរៀល ថយចុះ ១៣,២% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ១៨,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១២ –២០១៤

(ពាន់លានរៀល)




✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៩៩,៦ពាន់លានរៀល កើនឡើង ៣,៣% ធៀបនឹងខែមុននិងកើនឡើង ១២,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ::+០,៤% | (+៣៣,៣%) | ➢ នេសាទ:-៦៥,៩% | (-៣៨,៩%) |
| ➢ ចំណូលពន្ធដារ: -៩,៨% | (+៣៤,៧%) | ➢រុក្ខាប្រមាញ់:+២៧៣,២% | (+៣៦,២%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:-២,៤% | (-៧,២%) | ➢សម្បទានរ៉ែ: -៦៦,០% | (-៨៣,៩%) |
| ✧ កាស៊ីណូ :-៣៤,២% | (+៣៤,៤%) | ➢ អាកាសចរណ៍ស៊ីវិល:+៦៦៧,៩% | (+២២,៦%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៦២,៣% | (-៨៧,៤%) | ➢ផលទុននៃសកម្មភាពទេសចរណ៍: -៩៩,៩% | (+៨០,៣%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +៥៨,៥% | (-៥,៥%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍:+៦,០% | (+៣៧,៣%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែន និងទិដ្ឋាការ):+២៥,៧% | (+១៤,៩%) |
| | | ➢ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ:-០,៤% | (+១៤០,៩%) |

**២.២. ចំណាយថវិកាជាតិ៖** អនុវត្តបាន ៩១៩,៥ពាន់លានរៀល (*មធ្យមប្រចាំខែ ៥៨% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៧៩៥,៧ពាន់លានរៀល (*មធ្យមប្រចាំខែ ៧៩% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១២៣,៨ពាន់លានរៀល។

➢ចំណាយថវិកាជាតិកើនឡើង ២៤,៤%ធៀបនឹងខែមុននិងកើនឡើង ១០២,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង ២៦,៨% ធៀបនឹងខែមុននិងកើនឡើង ១១៨,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ:** ថវិកាជាតិនាខែនេះ មានឱនភាពចំនួន ១៩៣,៩ពាន់លានរៀល។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១២–២០១៤

(ពាន់លានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែវិច្ឆិកាឆ្នាំ២០១៤មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ$M_2$ មានចំនួន ៤១០៦៩ពាន់លានរៀល ថយចុះ ០,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣០,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។**ការថយចុះ** $M_2$ ក្នុងខែនេះ ជារួមបណ្តាលមកពីការថយចុះនៃប្រាក់បញ្ញើជារូបិយបណ្ណ ១,១%។

➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៧,២% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨២,៨% នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែវិច្ឆិកាឆ្នាំ២០១៤



តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៤

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៧% | ១៨,0% | ១៧,៧% | ១៧,៦% | ១៧,២% | ១៦,0% | ១៦,២% | ១៦,២% | ១៦,១% | ១៦,៥% | ១៧,២% | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៤% | ១៣,៥% | ១៣,៨% | ១៣,៨% | ១៣,២% | ១២,២% | ១២,៣% | ១២,៤% | ១២,៦% | ១២,៦% | ១៣,១% | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែវិច្ឆិកា២០១៤: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➤ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤៣0៤លានដុល្លារ កើនឡើង ៣,១% ធៀបនឹងខែមុន និង កើនឡើង ២២,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១២៣២0ពាន់លានរៀល ថយចុះ ១,៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២២,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *វិច្ឆិកា២០១៤* | *តុលា២០១៤* | *វិច្ឆិកា២០១៣* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល) | ៣៧៦២៧ | ៣៦៨0៥ | ២៩0៩៩ |
| ក្នុងនោះ ជារៀល | មិនទាន់មានតួលេខ | ៤៣៤ | ៤៤៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | | ៧៦៩៩ | ៥១0៤ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩% | ៥,៩៣% | ៥,៨៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,២% | ១៦,២% | ១១,៨% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៣% | ៤,២៣% | ៤,៣៤% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៥១% | ១១,៥១% | ១១,២% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែវិច្ឆិកាឆ្នាំ២០១៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➤ **កសិកម្ម**:

✓នេសាទសម្រេចបាន៥៣ពាន់តោន ថយចុះ៩%ធៀបនឹងខែមុន និងថយចុះ៣២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤ **ឧស្សាហកម្ម**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៤២៤,៤GWHមានការកើនឡើង៤%ធៀបនឹងខែមុន និងកើនឡើង២៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គសនីមានចំនួន ២១៥,១ GWH មានការថយចុះ២៥%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៥១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៤៨៩,៥ លានដុល្លារថយចុះ១%បើធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន —វិច្ឆិកា២០១៤ | ចំនួន—តុលា២០១៤ | ចំនួន—វិច្ឆិកា២០១៣ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៩ | ២៣ | ១៦ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១២៨៥ | ១២៧៦ | ១០៥៤ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | — | ២២ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | — | ២៤ |

➢**សំណង់** (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣៥២,០ពាន់ម៉ែត្រ² ថយចុះ ២៥% ធៀបនឹងខែមុន និងថយចុះ ១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១១១,៦លានដុល្លារ ថយចុះ ៣៤% ធៀបនឹងខែមុន និងថយចុះ ៥% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម៉² —វិច្ឆិកា២០១៤ | ពាន់ម៉² —តុលា២០១៤ | ពាន់ម៉² —វិច្ឆិកា២០១៣ |
|---|---|---|---|
| ▪ លំនៅឋាន | ២២៥,០ | ១៩៧,៤ | ១៤៧,៨ |
| ▪ ឧស្សាហកម្ម | ៦៦,៤ | ២១០,៦ | ១០១,៦ |
| ▪ទេសចរណ៍ | ២៩,៤ | ៣០,៩ | ១,៦ |
| ▪ពាណិជ្ជកម្ម | ២៤,១ | ១៨,៣ | ១៧,៣ |
| ▪ផ្សេងៗ | ០,០ | ២,០ | ១៤,៥ |
| អនុញ្ញាតសរុប | ៣៥២,០ | ៤៦៧,៤ | ៣៩២,៧ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ លំនៅដ្ឋាន ៦៣,៩% និង ឧស្សាហកម្ម ១៨,៩% នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—វិច្ឆិកា ២០១៤ | នាក់—តុលា ២០១៤ | នាក់—វិច្ឆិកា ២០១៣ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ ) | ៥២៤ | ៥២៣ | NA |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៤៥៦២ | ៤៦៧០ | ៣១២០ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៣០០០ | ១៩៦៨ | ១៧២៤ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៨៣៥ | ៤០៧៦ | ១៣៩៦ |

➢**វិនិយោគ**

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | វិច្ឆិកា២០១៤ | តុលា២០១៤ | វិច្ឆិកា២០១៣ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១១៩ | ២១ | ៥៩៩,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៨៣ | ០ | ០ |

| | | | |
|---|---|---|---|
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣៥<br>១ | ២១<br>(៨) | ៧៧,៣<br>(២៤,៧) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ៥២២,១ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១០ | ៨ | ៣៧ |
| បង្កើតការងារ (ពាន់នាក់) | ៥ | ៤ | ១៨,១ |

### ➤សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន –វិច្ឆិកា២០១៤ | ចំនួន–តុលា២០១៤ | ចំនួន–វិច្ឆិកា២០១៣ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២២១ | ៣២១ | ២៤៣ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៣ | ៤ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | | |

➤**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន ៥៥២,៤ពាន់តោន ថយចុះ ៩% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-២៤% | (+១០០%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+៤៣% | (-៦៧%) |
| ▪ កំពង់ផែកំពង់សោម:-៣% | (+១៦%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -១២% | (+២៩២%) |

### ➤ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២២,៤ | ១៥១% | ៩១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣៣,១ | ១៤% | ៤៣% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៨២,៣ | ២១% | ៩% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែវិច្ឆិកាមានចំនួន ៤០៦៦,៥ពាន់លានរៀល (ស្មើនឹង ១០១៦,៦លានដុល្លារ ស.រ.អា.) កើនឡើង ១,៨% ធៀបនឹងខែមុននិងកើនឡើង ៦% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +២៣,៩% | +៣៧,៨% | រថយន្តសរុប (ព.ល.រ) | +៨,៣% | +៣១,៧% |
| ប្រេងម៉ាស៊ូត | -១៤,១% | -៧,៧% | រថយន្តសរុប (គ្រឿង) | -១១,៤% | +៤២,៥% |
| ឧស្ម័ន | -១៧,១% | -២៥,១% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៩៩,៧% | -៩៩,៥% |
| អគ្គិសនីនាំចូល | +៦៣,១% | -៤១,៦% | ម៉ូតូ (គ្រឿង) | +១៨,៣% | +១២,៩% |
| ដែកសំណង់ | -២៩,៥% | +១,៩% | អង្ករ | -៦,១% | -៧៥,៩% |
| ស៊ីម៉ង់ត៍ | -១៩,៨% | +១៣,៩% | ផ្លែឈើនិងបន្លែ | +៦% | -៤១,៩% |
| គ្រឿងអេឡិចត្រូនិក | -៣៤,៨% | +៥៩,៧% | ជីនិងថ្នាំកសិកម្ម | -២០,១% | +៤៣,៣% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៧,២% | +៣៣,២% |

➡ **ការនាំចេញ** ខែវិច្ឆិកាឆ្នាំ២០១៤ មានចំនួន **២៦៧៤**ពាន់លានរៀល ស្មើនឹង **៦៦៨,៥**លានដុល្លារ ស.រ.អា. (**៦៥,៨**% នៃការនាំចូល) ថយចុះ ១៤,១% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ២,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៩២,៥% | -៩៥,៨% | ផលិតផលនេសាទ | +២៦% | -១៩,៨% |
| វាយនភណ្ឌនិងស្បែកជើង | -១៩,៦% | -១០,៧% | កៅស៊ូ | +១៦,៣% | +៦៥,៥% |
| អង្ករ | -១៧,៥% | -២៤,៦% | | | |

➡ក្នុងខែវិច្ឆិកានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ១៣៩២,៦ពាន់លានរៀល ស្មើនឹង ៣៤៨,១លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែវិច្ឆិកាឆ្នាំ២០១៤នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ. | សូចនាករ | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|
| ១ | ថ្លៃសាច់ជ្រូក | +៨,៨% | — |
| ២ | ថ្លៃផ្លែឈើ | +៩,៥% | |
| ៣ | ចំណូលពីអជ្ញាបណ្ណក្នុងស្រុក | -៨៧,៤% | មុខចំណូលសារពើពន្ធផ្សេងៗ |
| ៤ | ចំនួនរោងចក្រថ្មីដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម | -៤៤% | — |
| ៥ | ការនាំចេញអង្ករ | -២៤,៦% | — |

## ៧) សេចក្តីសន្និដ្ឋាន

១)សន្ទស្សន៍ថ្លៃទំនិញ (ធៀបនឹងខែដូចគ្នាឆ្នាំមុន) មានការថយចុះនៅក្នុងឆមាសទីពីរឆ្នាំ២០១៤ ដែលធ្វើឲ្យអតិផរណាឆ្នាំនេះនឹងមានអត្រាប្រហែល ៤%។ កត្តាសំខាន់នៃលទ្ធផលនេះគឺ ការធ្លាក់ចុះនៃថ្លៃប្រេង ដែលធ្វើឲ្យផលិតកម្មទំនិញ និងសេវាកម្មផ្សេងៗមានថ្លៃដើមទាប។

យ៉ាងណាក្តី មុខទំនិញមួយចំនួននៅតែមានសន្ទស្សន៍ថ្លៃខ្ពស់ដូចជា សាច់ជ្រូក និងផ្លែឈើ។ នេះដោយសារការផ្គត់ផ្គង់មិនអាចផ្គាប់តម្រូវការបានគ្រប់គ្រាន់។

ដោយកម្ពុជាជាប្រទេសកសិកម្ម ដូច្នេះវិស័យចិញ្ចឹមសត្វ ការដាំដុះដំណាំហូបផ្លែ និងបន្លែ គួរត្រូវបានពង្រឹងនិងពង្រីកឲ្យមានលក្ខណៈទ្រង់ទ្រាយធំ ប្រកបដោយបច្ចេកទេសខ្ពស់។ ការណ៍នេះតម្រូវឲ្យមានការឧបត្ថម្ភលើកទឹកចិត្ត ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ដល់វិនិយោគិនក្នុងស្រុក ឬក៏មានការទាក់ទាញការវិនិយោគធំៗពីបរទេស។

២)ការទាក់ទាញវិនិយោគិនឲ្យមកបណ្តាក់ទុននៅកម្ពុជា ប្រឈមនឹងបញ្ហាពីរធំៗគឺ៖

(ក) បញ្ហាដីសម្រាប់ការវិនិយោគ
(ខ) ការខ្វះកម្លាំងពលកម្មសម្រាប់បម្រើការងារក្នុងផលិតកម្ម។

ស្ថានភាពនេះខុសពីការបរិយាយក្នុងឯកសារផ្លូវការមួយចំនួនស្តីពីឧត្តមភាពវិនិយោគនៅកម្ពុជា ដែលលើកឡើងថាកម្ពុជាសំបូរដី និងមានកម្លាំងពលកម្មថោក។ ដូច្នេះ គោលនយោបាយដីធ្លី ជាពិសេសលក្ខខណ្ឌនៃការផ្តល់ដីសម្បទាន និងគោលនយោបាយនិយតកម្មក្នុងទីផ្សារពលកម្ម គួរតែជាគោលដៅអាទិភាពសម្រាប់រាជរដ្ឋាភិបាលក្នុងការធ្វើអន្តរាគមប្រកបដោយប្រសិទ្ធភាពលើសេដ្ឋកិច្ច និងសង្គមកិច្ច។

៣)កម្ពុជានឹងមានការផ្គត់ផ្គង់អគ្គិសនីគ្រប់ដណ្តប់ផ្ទៃប្រទេសទាំងមូលនៅក្នុងឆ្នាំ២០២០។

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១២/១៤ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់វិស្វករ បរិញ្ញាបត្រវិស្វកម្ម និងសញ្ញាបត្រ សាកលវិទ្យាល័យបច្ចេកវិទ្យា ជូនដល់និស្សិតវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេច ព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ២ | ០២/១២/១៤ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីមិទ្ទីងអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៦ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ៣ | ០៣/១២/១៤ ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងទិវាជនពិការកម្ពុជាលើកទី១៦ និងទិវាជនពិការអន្តរជាតិលើកទី៣២ ក្រោមប្រធានបទ "ផ្តល់លទ្ធភាពអាចប្រើប្រាស់បាន រួមបញ្ចូលទាំងមុខរបរការងារ និងបច្ចេកវិទ្យា ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៤ | ០៣/១២/១៤ ម៉ោង១៥:៣០នាទី | ដឹកនាំអង្គប្រជុំដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។<br>២-សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៤/១២/១៤ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់សិក្ខាកាម និស្សិតនៃវិទ្យាស្ថានខ្មែរជំនាន់ថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៦ | ០៥/១២/១៤ ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។<br>២-សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៧ | ០៥/១២/១៤ ម៉ោង១៩:០០នាទី | ចូលរួមពិសារភោជនីយអាហារ ក្នុងឱកាសគម្រប់ខួប២០ឆ្នាំ របស់ក្រុមហ៊ុន Compagnie Franaise de Commerce នៅក្រុមហ៊ុន CFC។ |
| ៨ | ០៩/១២/១៤ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការ ដើម្បីពិនិត្យលើការងារបន្ថែមសម្រាប់អគារលក់សំបុត្រពេលថ្ងៃ នៃមជ្ឈមណ្ឌលស្វាគមន៍ភ្ញៀវទេសចរណ៍ ខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១០/១២/១៤ ម៉ោង១៨:០០នាទី | ចូលរួមក្នុងឱកាសប្រារព្ធពិធីទិវាសិទ្ធិមនុស្សអន្តរជាតិ នៅ European Union Delegation។ |
| ១០ | ១៥/១២/១៤ ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ផែន សុវិជ្ជានោ** និងតំណាងក្រុមហ៊ុន Union នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៦/១២/១៤ ម៉ោង ១១:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **សុខ ចិន្តាសោភា** និងលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៧/១២/១៤ ម៉ោង១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និសីទអន្តរជាតិលើកទី៤ ស្តីពីទំនាក់ទំនងកម្ពុជា-ចិន នាសម័យសម្តេច ព្រះនរោត្តម និងពិធីបង្ហាញសៀវភៅ “ដែកនិងថ្មខ្មែរបុរាណ” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | ១៨/១២/១៤ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៤ | ១៨/១២/១៤ ម៉ោង១៥:៣០នាទី | ទទួលជួបពិភាក្សាការងារជាមួយលោក Nicolas Notebaert ប្រធាន និងលោក MENANTEAU CEO នៃក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ១៩/១២/១៤ ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារស្តីពីគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យា នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាមួយក្រុមហ៊ុនសាងសង់ហ្វាងគុង នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ៣០/១២/១៤ ម៉ោង១៦:៣០នាទី | ចុះហត្ថលេខាលើលិខិតប្តូរសារស្តីពី កិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់គម្រោងជួសជុល និងថែទាំ អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតប្តូរសារស្តីពីគម្រោងសាងសង់អគារអង្គរក្សនៃទីស្តីការគណៈរដ្ឋមន្ត្រី រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ |
| ១៧ | ៣១/១២/១៤ ម៉ោង០៩:៣០នាទី | ទទួលជួបពិភាក្សាការងារស្តីពីអគារសារមន្ទីរសព្វទស្សន៍ជាមួយលោក **Chung Dae Yong** ទីប្រឹក្សាយោបល់ នៃស្ថានទូតសាធារណរដ្ឋកូរ៉េ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈ រដ្ឋមន្ត្រី។ |
| ១៨ | ៣១/១២/១៤ ម៉ោង១៨:៣០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីបុណ្យឆ្លងឆ្នាំសកល ២០១៤ - ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |



រូបភាពក្នុងកិច្ចប្រជុំស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣



រូបភាពក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in